**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខៈ ២៧៦២ MIH / ២០១៧

# ប្រកាស
## ស្តីពី
## ការកំណត់គោលការណ៍ និងនីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប នៅកម្ពុជា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៧/០១៦ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា៣៧ មាត្រា៣៨ មាត្រា១០៩ និងមាត្រា១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៧/០១៧ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងទទួលស្គាល់សុពលភាព នៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ៤៥១ MIH/2014 ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខៈ (៨៥៥) ២៣ ២១១ ៧៧៥
ទូរសារលេខៈ (៨៥៥) ២៣ ២១១ ៨៩៤
អ៊ីម៉ែលៈ mih.smcabinet@gmail.com

## សម្រេច
## ផ្នែកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១._ គោលបំណង**

ប្រកាសនេះមានគោលបំណងអនុវត្តការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប នៅកម្ពុជា អនុលោមតាមច្បាប់ប្រកាសនីយបត្រតក្កកម្ម និងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប។

**ប្រការ២._ គោលដៅ**

ប្រកាសនេះ មានគោលដៅ៖

- កំណត់អំពីនីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប នៅកម្ពុជា
- កំណត់បែបបទនៃការរក្សាសុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប នៅកម្ពុជា
- កំណត់យន្តការទទួលបន្ទុកពិនិត្យ និងគ្រប់គ្រងប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលត្រូវបានទទួលស្គាល់សុពលភាព នៅកម្ពុជា ។

**ប្រការ៣._ វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសំណុំលិខិតស្នើសុំទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប អនុលោមតាមច្បាប់ប្រកាសនីយបត្រតក្កកម្ម និងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប។

**ប្រការ៤._ ភារកិច្ចរបស់នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី**

នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី ត្រូវទទួលពិនិត្យសំណុំលិខិតស្នើសុំទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា ដើម្បីធ្វើការគ្រប់គ្រង និងការពារកម្មសិទ្ធិបញ្ញារបស់តក្កករ ដែលបានបង្កើតតក្កកម្ម និងការច្នៃប្រឌិត អនុលោមតាមច្បាប់ប្រកាសនីយបត្រតក្កកម្ម និងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប។

**ប្រការ៥._ វាក្យស័ព្ទ**

វាក្យស័ព្ទដែលប្រើក្នុងប្រកាសនេះ ត្រូវបានបកស្រាយដូចខាងក្រោម៖

- **ច្បាប់ប្រកាសនីយបត្រតក្កកម្ម** សំដៅដល់ច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០៥ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ និងច្បាប់ស្តីពីវិសោធនកម្មមាត្រា៣៧ មាត្រា៣៨ មាត្រា១០៩ និងមាត្រា



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com

១៣៦ នៃច្បាប់ស្តីពីប្រកាសនីយបត្រតក្កកម្ម វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ និងគំនូរឧស្សាហកម្ម ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៧/០១៦ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧។

- **សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុប** មានន័យថា ជាសំណុំលិខិតស្នើសុំ សម្រាប់ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលបានដាក់សុំនៅក្រោមអនុសញ្ញាប្រកាសនីយបត្រតក្កកម្មអឺរ៉ុប " ហៅកាត់ថា (EPC) " ក៏ដូចជាសំណុំលិខិតស្នើសុំអន្តរជាតិ ដែលបានដាក់នៅក្រោមសន្ធិសញ្ញាកិច្ចសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម " ហៅកាត់ថា (PCT) " ដែលការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប " ហៅកាត់ថា (EPO) " ត្រូវបានជ្រើសរើសជាការិយាល័យជ្រើសរើស ឬជាការិយាល័យជ្រើសតាំង ហើយដែលត្រូវបានផ្តល់កាលបរិច្ឆេទសុំចុះបញ្ជីអន្តរជាតិ និងដែលប្រទេសកម្ពុជាត្រូវបានជ្រើសរើស។

- **ប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលត្រូវបានទទួលស្គាល់សុពលភាព** មានន័យថា ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលត្រូវបានផ្តល់ដោយការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប លើសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលបានស្នើសុំទទួលស្គាល់សុពលភាព នៅក្នុងប្រទេសកម្ពុជា។

- **ដំណាក់កាលអឺរ៉ុប** មានន័យថា ជាសំណុំលិខិតប្រកាសនីយបត្រតក្កកម្មអន្តរជាតិ ដែលបានដាក់ក្រោមសន្ធិសញ្ញាកិច្ចសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ហើយបានកំពុងដំណើរការត្រួតពិនិត្យ និងផ្តល់ប្រកាសនីយបត្រតក្កកម្ម ដោយស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប។

- **សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មជាតិ** មានន័យថា ជាសំណុំលិខិតប្រកាសនីយបត្រតក្កកម្ម ដែលបានដាក់សុំអនុលោមតាមច្បាប់ប្រកាសនីយបត្រតក្កកម្ម នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម «ហៅកាត់ថា (MIH)» ។

- **ប្រកាសនីយបត្រតក្កកម្មជាតិ** មានន័យថា ជាប្រកាសនីយបត្រតក្កកម្ម ដែលត្រូវបានផ្តល់លើសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មជាតិ។

- **រដ្ឋមន្ត្រី** សំដៅដល់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។
- **មន្ត្រីកាន់កាប់បញ្ជី** សំដៅដល់ប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ។
- **នាយកដ្ឋានទទួលបន្ទុកចុះបញ្ជី** សំដៅដល់នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ។

## ជំពូកទី២
## នីតិវិធីនៃការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប

### ប្រការ៦._ ការទទួលស្គាល់សុពលភាព នៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប

ពាក្យសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុប និងប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលត្រូវបានទទួលស្គាល់សុពលភាពនៅកម្ពុជា យោងតាមបទប្បញ្ញត្តិខាងក្រោមនេះ ត្រូវមានប្រសិទ្ធភាពនិងត្រូវមានលក្ខខណ្ឌដូចគ្នាទៅនឹងសំណុំលិខិតប្រកាសនីយបត្រតក្កកម្មជាតិ និងប្រកាសនីយបត្រតក្កកម្មជាតិ អនុលោមតាមច្បាប់ប្រកាសនីយបត្រតក្កកម្ម។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (០២៣) ២៣២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com

## ប្រការ៧._ ការស្នើសុំទទួលស្គាល់សុពលភាព

ការស្នើសុំទទួលស្គាល់សុពលភាពប្រកាសនីយបត្រតក្កកម្មមានដូចខាងក្រោម៖

១- សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុប និងប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលបានផ្តល់ឲ្យតាមសំណុំលិខិតស្នើសុំនេះ ត្រូវបានទទួលស្គាល់សុពលភាពនៅក្នុងប្រទេសកម្ពុជា តាមសំណើរបស់អ្នកដាក់ពាក្យសុំ។ សំណើសុំទទួលស្គាល់សុពលភាព ត្រូវបានទទួលយកចំពោះសំណុំលិខិតប្រកាសនីយបត្រតក្កកម្មអឺរ៉ុបណាមួយ ដែលបានដាក់នៅថ្ងៃ ឬបន្ទាប់ពីថ្ងៃចូលជាធរមាននៃកិច្ចព្រមព្រៀងទទួលស្គាល់សុពលភាព រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប។

២- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបោះពុម្ពផ្សាយពាក្យសុំទទួលស្គាល់សុពលភាពប្រកាសនីយបត្រតក្កកម្មឲ្យបានឆាប់រហ័ស បន្ទាប់ពីទទួលបានការជូនដំណឹងពីការិយាល័យប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលបញ្ជាក់ថាកម្រៃនៃការស្នើសុំទទួលស្គាល់សុពលភាពប្រកាសនីយបត្រតក្កកម្មត្រូវបានបង់រួច ប៉ុន្តែមិនមែនធ្វើឡើងនៅមុនពេលផុតកំណត់នៃរយៈពេល ១៨ខែ គិតចាប់ពីកាលបរិច្ឆេទសុំចុះបញ្ជី ឬកាលបរិច្ឆេទអាទិភាពដំបូង ប្រសិនបើមានការអះអាងអាទិភាព។

៣- សំណើសុំទទួលស្គាល់សុពលភាពប្រកាសនីយបត្រតក្កកម្ម អាចត្រូវបានដកនៅពេលណាមួយក៏បាន។ សំណើសុំទទួលស្គាល់សុពលភាពនេះត្រូវបានចាត់ទុកថាបានដកចេញ នៅពេលដែលកម្រៃកំណត់លើការស្នើសុំទទួលស្គាល់សុពលភាពមិនត្រូវបានបង់ទាន់ពេលវេលា ឬនៅពេលសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុបត្រូវបានបដិសេធ ដកចេញ ឬចាត់ទុកថាដកចេញនៅទីបញ្ចប់។ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងបោះពុម្ពផ្សាយឲ្យបានឆាប់ប្រសិនបើការស្នើសុំសុពលភាពត្រូវបានចុះផ្សាយរួចហើយ អនុលោមតាមចំណុច២ នៃប្រការនេះ។

## ប្រការ៨._ ប្រសិទ្ធភាពនៃសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុប

សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលត្រូវបានផ្តល់កាលបរិច្ឆេទសុំចុះបញ្ជី ត្រូវមានភាពដូចគ្នាទៅនឹងសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មថ្នាក់ជាតិ ដែលស្របតាមការប្រកាសអាទិភាព នៃសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុប។

## ប្រការ៩._ ប្រសិទ្ធភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប

ប្រសិទ្ធភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបមានដូចខាងក្រោម៖

១- អនុលោមតាមចំណុច២ ដល់ចំណុច៧ នៃប្រការនេះ ប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលត្រូវបានទទួលស្គាល់សុពលភាពចាប់ពីកាលបរិច្ឆេទបោះពុម្ពផ្សាយ អំពីការផ្តល់ប្រកាសនីយបត្រតក្កកម្ម ដោយស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ត្រូវមានសិទ្ធិដូចគ្នា និងដូចអ្វីដែលទទួលបានដោយប្រកាសនីយបត្រតក្កកម្មជាតិ អនុលោម តាមច្បាប់ប្រកាសនីយបត្រតក្កកម្ម។

២- ក្នុងរយៈពេល៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទដែលបញ្ជាក់អំពីការផ្តល់ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលបានបោះពុម្ពផ្សាយ ម្ចាស់នៃប្រកាសនីយបត្រតក្កកម្មត្រូវផ្តល់ឱ្យទៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម នូវសេចក្តីបកប្រែជាភាសាខ្មែរ និងជាភាសាអង់គ្លេស ហើយត្រូវបង់កម្រៃសម្រាប់ការបោះពុម្ពផ្សាយ តាមការកំណត់។

៣- ប្រសិនបើប្រកាសនីយបត្រតក្កកម្មអឺរ៉ុបត្រូវបានរក្សានៅក្នុងទម្រង់កែសម្រួល តាមលទ្ធផលនៃការជំទាស់ ឬការស្នើសុំកម្រិតទំហំនៃសេចក្តីអះអាងដែលបានដាក់ពាក្យសុំជាមួយស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ម្ចាស់នៃ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
អ៊ីមែល: mih.smcabinet@gmail.com

ប្រកាសនីយបត្រតក្កកម្មត្រូវផ្តល់អត្ថបទបកប្រែសេចក្តីអះអាង ដែលបានបកប្រែជាភាសាខ្មែរ និងភាសាអង់គ្លេសដល់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងត្រូវបង់ថ្លៃសេវាសម្រាប់ការបោះពុម្ពផ្សាយ នៅក្នុងរយៈពេល៣(បី)ខែ នៃកាលបរិច្ឆេទដែលការសម្រេចរក្សាសុពលភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុបក្នុងទម្រង់កែសម្រួល ឬក្នុងទម្រង់ការកម្រិតដែលត្រូវបានបោះពុម្ពផ្សាយ។

៤- ក្នុងករណីអត្ថបទនៃសេចក្តីអះអាងមានការយោងទៅសញ្ញា ដែលបានប្រើប្រាស់ក្នុងគំនូសបង្ហាញគំនូសបង្ហាញនោះត្រូវដាក់ភ្ជាប់មកជាមួយការបកប្រែដូចមានចែងក្នុងចំណុច២ ឬចំណុច៣ នៃប្រការនេះ។

៥- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបោះពុម្ពផ្សាយឲ្យបានឆាប់រហ័សនូវសេចក្តីបកប្រែណាមួយដែលត្រឹមត្រូវ ហើយដែលបានដាក់ជូនមកនោះ អនុលោមតាមចំណុច២ ឬចំណុច៣ នៃប្រការនេះ។

៦- ប្រសិនបើការបកប្រែដែលបានបញ្ជាក់នៅក្នុងចំណុច២ ឬចំណុច៣ នៃប្រការនេះ មិនត្រូវបានផ្តល់ជូនក្នុងពេលវេលាកំណត់ ឬកម្រៃបោះពុម្ពផ្សាយមិនត្រូវបានបង់នៅក្នុងពេលវេលាកំណត់ទេនោះ ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលបានទទួលស្គាល់សុពលភាពនឹងត្រូវបានចាត់ទុកថា បានបោះបង់ចោលតាំងពីដើមរៀងមក។ សេចក្តីបកប្រែនេះអាចអនុញ្ញាតឲ្យផ្តល់ឲ្យ ក្នុងអំឡុងពេលបី(៣)ខែបន្ថែមទៀត ចាប់ពីពេលដែលបានផុតកំណត់ ដូចមានចែងក្នុងចំណុច២ និងចំណុច៣ នៃប្រការនេះ។

៧- ប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលត្រូវបានទទួលស្គាល់សុពលភាព ត្រូវបានចាត់ទុកថាមិនមានប្រសិទ្ធភាពដូចមានចែងក្នុងចំណុច១ នៃប្រការនេះ ចំពោះករណីដែលប្រកាសនីយបត្រតក្កកម្ម ត្រូវបានលុបចោលនៅក្នុងដំណើរការនីតិវិធីជំទាស់ ឬនៅក្នុងកិច្ចដំណើរការនីតិវិធីវិនិច្ឆ័យ ឬការកម្រិតនៅក្នុងនីតិវិធីកម្រិតទំហំនៃសេចក្តីអះអាងដែលធ្វើឡើងដោយស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ។

## ប្រការ១០_ អត្ថបទត្រឹមត្រូវនៃសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ឬប្រកាសនីយបត្រតក្កកម្មអឺរ៉ុប

អត្ថបទត្រឹមត្រូវនៃសំណុំលិខិតទាំងនេះ មានដូចខាងក្រោម៖

១- អត្ថបទនៃសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ឬប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលជាភាសានៃដំណើរការនីតិវិធីនៅចំពោះមុខស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ត្រូវតែជាអត្ថបទត្រឹមត្រូវនៅក្នុងដំណើរការនីតិវិធីប្រកាសនីយបត្រតក្កកម្មនៅកម្ពុជា។

២- ទោះបីជាប្រកាសនីយបត្រតក្កកម្ម ដែលបានបកប្រែជាភាសាដែលកំណត់សម្រាប់ការផ្តល់ការការពារប្រកាសនីយបត្រតក្កកម្មនោះ មានវិសាលភាពការពារចង្អៀតជាងអត្ថបទនៃភាសាដើមក៏ដោយ នោះការបកប្រែអនុលោមតាមប្រការ៩ ត្រូវបានចាត់ទុកថាជាអត្ថបទត្រឹមត្រូវ លើកលែងតែក្នុងដំណើរការមោឃភាព។

៣- ម្ចាស់ប្រកាសនីយបត្រតក្កកម្ម នៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលត្រូវបានទទួលស្គាល់សុពលភាពអាចដាក់ជូននូវការកែតម្រូវនៃការបកប្រែនៅពេលណាក៏បាន។ ការបកប្រែដែលបានកែតម្រូវ នៃសេចក្តីអះអាងរបស់ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ដែលត្រូវបានទទួលស្គាល់សុពលភាពនោះ មិនត្រូវមានប្រសិទ្ធភាពផ្នែកច្បាប់ឡើយ រហូតទាល់តែត្រូវបានផ្សព្វផ្សាយជាសាធារណៈដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខៈ (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com

៤- បុគ្គលដែលប្រើប្រាស់តក្កកម្ម ឬធ្វើឲ្យមានប្រសិទ្ធភាព និងរៀបចំដាក់លាក់ ក្នុងការប្រើប្រាស់តក្កកម្មនោះក្នុងគោលបំណងល្អ នឹងមិនត្រូវចាត់ទុកថាជាការរំលោភបំពានប្រកាសនីយបត្រតក្កកម្ម ក្នុងអត្ថន័យនៃការបកប្រែដើមដំបូង និងក្នុងអត្ថន័យបន្ទាប់ពីការកែតម្រូវនៃការបកប្រែដែលមានប្រសិទ្ធភាព ហើយអាចបន្តការប្រើប្រាស់តក្កកម្មនោះ នៅក្នុងអាជីវកម្មរបស់គាត់ ឬសម្រាប់សេចក្តីត្រូវការរបស់គាត់ដោយគ្មានការបង់កម្រៃអ្វីឡើយ។

## ប្រការ១១._ សិទ្ធិនៃកាលបរិច្ឆេទមុន

សិទ្ធិនៃកាលបរិច្ឆេទមុន មានដូចជា៖

១- សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលបានបង់កម្រៃទទួលស្គាល់សុពលភាព និងប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលត្រូវបានទទួលស្គាល់សុពលភាពរួចហើយ ត្រូវចាត់ទុកថាជាស្នាដៃតក្កកម្មមុនមានប្រសិទ្ធភាពដូចគ្នានឹងសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មជាតិ និងប្រកាសនីយបត្រតក្កកម្មជាតិ។

២- សំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្មជាតិ និងប្រកាសនីយបត្រតក្កកម្មជាតិ ត្រូវចាត់ទុកថាមានប្រសិទ្ធភាពដូចគ្នានឹងប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលត្រូវបានទទួលស្គាល់សុពលភាព ។

## ប្រការ១២._ ការការពារដែលកើតឡើងក្នុងពេលតែមួយ

ក្នុងករណីប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលត្រូវបានទទួលស្គាល់សុពលភាព និងប្រកាសនីយបត្រតក្កកម្មជាតិមានកាលបរិច្ឆេទសុំចុះបញ្ជីដូចគ្នា ឬប្រសិនបើកាលបរិច្ឆេទអាទិភាពដែលមានការប្រកាសអាទិភាពដូចគ្នា ត្រូវបានផ្តល់ឲ្យបុគ្គលដែលជាម្ចាស់តែមួយ ឬផ្តល់ឲ្យអ្នកស្នងមរតករបស់គាត់សម្រាប់តក្កកម្មដូចគ្នា នោះប្រកាសនីយបត្រតក្កកម្មជាតិដែលដូចគ្នាទៅនឹងតក្កកម្មនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលត្រូវបានទទួលស្គាល់សុពលភាព នឹងមិនមានប្រសិទ្ធភាពទេ ដោយគិតចាប់ពីកាលបរិច្ឆេទផុតកំណត់នៃការប្តឹងជំទាស់ទៅនឹងការផ្តល់ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ឬគិតចាប់ពីកាលបរិច្ឆេទទទួលយកការសម្រេចចុងក្រោយនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប។

## ប្រការ១៣._ ភាពអាចអនុវត្តបានអនុសញ្ញាប្រកាសនីយបត្រតក្កកម្មអឺរ៉ុប

បទប្បញ្ញត្តិនៃអនុសញ្ញាប្រកាសនីយបត្រតក្កកម្មអឺរ៉ុប និងវិធានដែលពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញានេះ នឹងមិនត្រូវយកមកអនុវត្តនៅកម្ពុជាទេ លើកលែងតែមានចែងក្នុងប្រកាសនេះ។

# ផ្នែកទី ៣

# ការបង់កម្រៃ និងសេវាផ្សេងៗ

## ប្រការ១៤._ កម្រៃនៃការទទួលស្គាល់សុពលភាព

កម្រៃនៃការទទួលស្គាល់សុពលភាពត្រូវអនុវត្តដូចខាងក្រោម៖

១- កម្រៃនៃការទទួលស្គាល់សុពលភាព អនុលោមតាមប្រការ៧(២) ត្រូវបានបង់នៅស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប បន្ទាប់ពីកាលបរិច្ឆេទនៃការបោះពុម្ពផ្សាយសុពលភាពនេះ ក្នុងព្រឹត្តិបត្រប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលបោះពុម្ពផ្សាយរបាយការណ៍ការស្រាវជ្រាវអឺរ៉ុប ប៉ុន្តែមិនត្រូវលើសពីរយៈពេល៦(ប្រាំមួយ)ខែនៃកាលបរិច្ឆេទនោះ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: mih.smcabinet@gmail.com

ឬនៅក្នុងអំឡុងពេលអនុវត្តការងារដែលបានតម្រូវ សម្រាប់ចូលទៅក្នុងដំណាក់កាលអឺរ៉ុបនៃសំណុំលិខិតស្នើសុំអន្តរជាតិ អនុលោមតាមអត្ថន័យវាក្យខណ្ឌ២ នៃប្រការ៥ ។

២- កម្រៃនៃការទទួលស្គាល់សុពលភាព នៅតែអាចអនុញ្ញាតឲ្យបង់នៅក្នុងរយៈពេលបន្ថែម ចំនួន២(ពីរ)ខែ បន្ទាប់ពីផុតរយៈពេល ដូចមានចែងក្នុងចំណុច១ នៃប្រការនេះ ប៉ុន្តែតម្រូវឲ្យបង់កម្រៃបន្ថែមចំនួន៥០% នៅក្នុងរយៈពេលបន្ថែមនេះ។

៣- ការបង់កម្រៃនៃការទទួលស្គាល់សុពលភាពត្រូវអនុវត្តដូចគ្នា ដោយអនុលោមតាមបទបញ្ញាទាក់ទងទៅនឹងការបង់កម្រៃរបស់ស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប។ កម្រៃនៃការទទួលស្គាល់សុពលភាពដែលបានបង់រួចហើយ មិនអាចដកវិញបានទេ។

## ប្រការ១៥._ កម្រៃប្រចាំឆ្នាំសម្រាប់ប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលមានសុពលភាព

ការបង់កម្រៃប្រចាំឆ្នាំខាងលើនេះ ត្រូវអនុវត្តដូចខាងក្រោម ៖

១- កម្រៃប្រចាំឆ្នាំសម្រាប់ប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលត្រូវបានទទួលស្គាល់សុពលភាពនៅកម្ពុជា ត្រូវបង់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម សម្រាប់ឆ្នាំជាបន្តបន្ទាប់ រាប់គិតបន្ទាប់ពីឆ្នាំនៃការផ្តល់ប្រកាសនីយបត្រតក្កកម្មអឺរ៉ុប ត្រូវបានបោះពុម្ពផ្សាយនោះ។

២- ប្រសិនបើកម្រៃប្រចាំឆ្នាំសម្រាប់ប្រកាសនីបត្រតក្កកម្មអឺរ៉ុបដែលត្រូវបានទទួលស្គាល់សុពលភាព បានបង់ក្នុងរយៈពេល២(ពីរ)ខែ ចាប់ពីពេលដែលការផ្តល់ប្រកាសនីយបត្រតក្កកម្ម ត្រូវបានបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិបត្រប្រកាសនីយបត្រតក្កកម្មអឺរ៉ុប នឹងត្រូវចាត់ទុកថាបានបង់ប្រាក់ត្រឹមត្រូវនៅក្នុងឆ្នាំនោះ។

## ប្រការ១៦._ ការបង់កម្រៃសេវាសាធារណៈនៅកម្ពុជា

ការបង់កម្រៃ និងសេវាផ្សេងៗនៅកម្ពុជា ដែលពាក់ព័ន្ធនឹងការទទួលស្គាល់សុពលភាពនៃប្រកាសនីយបត្រតក្កកម្មអឺរ៉ុប នៅកម្ពុជា ត្រូវអនុវត្តតាមប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈ រវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

# ផ្នែកទី ៤

# ការដោះស្រាយទំនាស់ និងកិច្ចសហការ

## ប្រការ១៧._ ការដោះស្រាយទំនាស់

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានសមត្ថកិច្ចសម្របសម្រួល និងដោះស្រាយទំនាស់ដែលពាក់ព័ន្ធនឹងការទទួលស្គាល់សុពលភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុបនៅកម្ពុជា។ ក្នុងករណីមិនអាចដោះស្រាយបាន គូភាគីដែលពាក់ព័ន្ធអាចដោះស្រាយតាមផ្លូវតុលាការដែលមានសមត្ថកិច្ច។

## ប្រការ១៨._ កិច្ចសហការ

នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវសហការជាមួយស្ថាប័នប្រកាសនីយបត្រតក្កកម្មអឺរ៉ុប និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដើម្បីជំរុញការការពារប្រកាសនីយបត្រតក្កកម្មអឺរ៉ុបដែលត្រូវបានទទួលស្គាល់សុពលភាព នៅកម្ពុជា។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: mih.smcabinet@gmail.com

## ផ្នែកទី ៥

## អវសានប្បញ្ញត្តិ

### ប្រការ១៩._ និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

### ប្រការ២០._ សមត្ថកិច្ចអនុវត្ត

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ គ្រប់អង្គភាពក្រោមឱវាទក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងនីតិបុគ្គល ឬរូបវន្តបុគ្គលដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ។

### ប្រការ២១._ ប្រសិទ្ធភាព

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃ ខែ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ត្រូវនឹងថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**<u>កន្លែងទទួល៖</u>**

- ខុទ្ទកាល័យ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ២០
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com